00878435

E236/3/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 01 / 2013
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងផ្នែកគ្រប់គ្រងតុលាការ

**កម្មវត្ថុ៖** ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង សុំដាក់ឯកសារថ្មីៗចូលក្នុងសំណុំរឿងពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី ហ៊ុន ឈុនលី (ឯកសារ E236/3)។

1. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើពីសហព្រះរាជអាជ្ញា សុំដាក់ឯកសារចូលក្នុងសំណុំរឿង ដើម្បីប្រើប្រាស់ក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់សាក្សី ហ៊ុន ឈុនលី (ឯកសារ E236/3)។ តាមរយៈការប្រាស្រ័យទាក់ទងតាមអ៊ីមែល ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់ស្តីទីនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់គ្រប់ភាគីទាំងអស់ថា សំណើសុំរបស់សហព្រះរាជអាជ្ញាត្រូវបានសម្រេចបដិសេធចោល។ អនុស្សរណៈនេះសូមផ្តល់នូវសំអាងហេតុទាំងឡាយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានសម្រេចបដិសេធសំណើសុំនោះ។

2. ដើម្បីឲ្យមានការទទួលយកឯកសារនានាស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ជាធម្មតា ភាគីដែលស្នើសុំត្រូវធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ ឬពុំអាចរកបានឡើយ ទោះបីជាខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ (ឧទាហរណ៍

ឯកសារ E190)។ ឯកសារដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានធ្វើឡើងជាមួយនឹងសាក្សី នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧។ តាមរយៈការទទួលយកឯកសារដោយខ្លួនឯង សហព្រះរាជអាជ្ញាពិតជាធ្លាប់មានឯកសារនេះចាប់តាំងពីពេលនោះហើយ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាមិនបានបំពេញលក្ខខណ្ឌតម្រូវទាំងឡាយដែលមានចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ។

3. ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការបដិសេធសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ឯកសារនេះនៅចំពោះមុខខ្លួន។ អង្គជំនុំជម្រះក៏សូមណែនាំដល់ផ្នែកគ្រប់គ្រងតុលាការ ឲ្យដកឯកសារដែលបានស្នើសុំចេញពីសំណុំរឿងផងដែរ ពីព្រោះបច្ចុប្បន្ន ឯកសារនេះហាក់បីដូចជាបានដាក់ជាឯកសារភ្ជាប់ទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា (ឯកសារ E236/3.1)។